KINGDOM OF CAMBODIA
NATION RELIGION KING

STATE SECRETARIAT OF CIVIL AVIATION

No : 236 SSCA

Date: 17 / Nov / 2021

# NOTICE
## (REVISION 11: 17 NOVEMBER 2021)

****

**The State Secretariat of Civil Aviation (SSCA) of the Kingdom of Cambodia** presents its compliment to all local airlines of Cambodia, foreign airlines, and commercial private jets (air operators) operating into and out of Phnom Penh, Siem Reap, and Preah Sihanouk International Airports (PNH/REP/KOS) and would like to update the latter on the latest revised measures for prevention, containment, and response to the spread of the COVID-19 as issued by the Royal Government of Cambodia, as follows:

1. All air travelers who wish to enter the Kingdom of Cambodia **MUST** strictly follow the latest Decision on the Revision of Requirements for Travels, Implementation of Health Measures and Quarantines for Travelers Entering Cambodia in the Context of New Normal Trajectory **dated 16 November 2021, Ref: 504 S.K.L** as an **Annex 1** to this Notice.
2. For clarity,

***A.*** **Fully Vaccinated Passengers for COVID-19 (Both Cambodian and Foreign Nationals)**
   i. Certificate or Document Test for COVID-19 negative status (PCR) with the validity within 72 hours upon arrival in Cambodia
   ii. Proof of Certificate or Document of Vaccination
   iii. Rapid Test of COVID-19 upon arrival
      a. Negative: No quarantine required
      b. Positive: COVID-19 treatments

***B.*** **Unvaccinated or Not Fully Vaccinated Passengers for COVID-19 (Both Cambodian and Foreign Nationals)**
   i. Certificate or Document Test for COVID-19 negative status (PCR) with the validity within 72 hours upon arrival in Cambodia
   ii. Booking hotels for self-quarantine or Deposit with 2,000 United States Dollars for quarantine arranged by local authorities (ONLY FOR FOREIGN NATIONALS)
   iii. Rapid Test of COVID-19 upon arrival:
      a. Negative:
         - 14-day quarantine
         - Retest of COVID-19 by PCR on 13th day of quarantine
      b. Positive: COVID-19 treatments

***C.*** **Visa Application (Foreign Nationals)**
   i. Visa Application through the Embassy or Consulate of the Kingdom of Cambodia
   ii. Not available for **Visa on Arrival**, excepted, traveler holding the passport of country which has an agreement with the Kingdom of Cambodia for **Visa Exemption** as **Annex 2**

***D.*** **Responsibilities of Expenses for COVID-19 Treatments in the Case of Foreign Nationals**:
   i. Diplomats and Officials of International Organizations holding **Visa A and Visa B**: Self-responsibilities of expenses for COVID-19 treatments
   ii. Other Foreign Nationals: Encourage, but not **COMPULSORY**, to purchase health insurance for expenses of COVID-19 treatments (COVID-19 Health Insurance Policy) through https://www.forteinsurance.com/covid-19-insurance/.

***E.*** **For Air Operators' Crews Who Are Entering the Kingdom of Cambodia**: Refer to Attached Letter Ref: 179 dated 14 August 2020 issued by the Ministry of Health as **ANNEX 3**.

**Effective: IMMEDIATE**

**STATE SECRETARIAT OF CIVIL AVIATION**

#44 Phnom Penh International Airport, Russian Federation Blvd., Phum Ta Ngoun, Sangkat Kakap, Khan Por Senchey, Phnom Penh
Tel: (855) 23 890 198 / Fax: (855) 23 890 102 / (855) 23 890 108
Email: ssca-int@civilaviation.gov.kh / Website: www.civilaviation.gov.kh

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

លេខ ៥០៤ ស.ខ.ល

# សេចក្តីសម្រេច

## ស្តីពី

## ការកែសម្រួលលក្ខខណ្ឌធ្វើដំណើរ ការអនុវត្តវិធានការសុខាភិបាល និងការធ្វើចត្តាឡីស័ក នៅកម្ពុជាសម្រាប់អ្នកដំណើរចូលកម្ពុជា ស្របតាមគន្លងប្រក្រតីភាពថ្មី

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល

## និងជាប្រធានគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២១/០០៤ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ៣៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ៥៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការរដ្ឋបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត



ទីស្តីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

- បានឃើញអនុក្រឹត្យលេខ៨៥ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩
- យោងតាមតម្រូវការចាំបាច់របស់គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩

## សម្រេច

**ប្រការ១ .–**

ត្រូវបានកែសម្រួលលក្ខខណ្ឌធ្វើដំណើរ ការអនុវត្តវិធានការសុខាភិបាល និងការធ្វើចត្តាឡីស័កនៅកម្ពុជា សម្រាប់អ្នកដំណើរចូលកម្ពុជាស្របតាមគន្លងប្រក្រតីភាពថ្មីដូចខាងក្រោម÷

១-អ្នកដំណើរដែលបានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសមូលដ្ឋានបានពេញលេញ ត្រូវភ្ជាប់មកជាមួយនូវបណ្ណ ឬវិញ្ញាបនបត្រចាក់វ៉ាក់សាំងកូវីដ-១៩ ដែលបញ្ជាក់ពីការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសមូលដ្ឋានបានពេញលេញ និងវិញ្ញាបនបត្របញ្ជាក់ថាគ្មានជំងឺកូវីដ-១៩ (តេស្ត PCR) ក្នុងរយៈពេល ៧២ ម៉ោង មុនពេលមកដល់កម្ពុជា ទទួលស្គាល់ដោយអាជ្ញាធរសុខាភិបាលនៃប្រទេសសាមី ឬប្រទេសសំណាក់ចុងក្រោយមុនចាកចេញមកកាន់កម្ពុជា។ ពេលមកដល់កម្ពុជា ត្រូវធ្វើតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ (Rapid Test) នៅច្រកចូលប្រទេស ហើយត្រូវរង់ចាំលទ្ធផលតេស្តនេះ។ បន្ទាប់ពីទទួលបានលទ្ធផលតេស្តកូវីដ-១៩ អវិជ្ជមាន បុគ្គលមិនតម្រូវឱ្យធ្វើចត្តាឡីស័កឡើយ និងអាចធ្វើដំណើរដោយសេរីទូទាំងប្រទេសកម្ពុជា។ ក្នុងករណីទទួលបានលទ្ធផលតេស្តកូវីដ-១៩ វិជ្ជមាន អ្នកជំងឺអាចដាក់ឱ្យព្យាបាលឬបញ្ជូនទៅកន្លែងព្យាបាលដែលអនុញ្ញាតដោយក្រសួងសុខាភិបាល។

២-ចំពោះអ្នកដំណើរដែលមិនបានចាក់វ៉ាក់សាំងកូវីដ-១៩ ឬមិនទាន់ចាក់វ៉ាក់សាំងកូវីដ-១៩ ដូសមូលដ្ឋានបានពេញលេញ ហើយធ្វើដំណើរចូលមកកម្ពុជា តម្រូវឱ្យយកសំណាកធ្វើតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ (Rapid Test) នៅច្រកចូលប្រទេស ហើយត្រូវរង់ចាំលទ្ធផលតេស្តនេះ។ បន្ទាប់ពីទទួលបានលទ្ធផលតេស្តកូវីដ-១៩ អវិជ្ជមាន បុគ្គលតម្រូវឱ្យធ្វើចត្តាឡីស័ករយៈពេល ១៤ថ្ងៃ នៅទីកន្លែងដែលកំណត់ដោយក្រសួងសុខាភិបាល ឬអាជ្ញាធរមានសមត្ថកិច្ច និងធ្វើតេស្តដោយម៉ាស៊ីន PCR នៅថ្ងៃទី១៣ នៃការធ្វើចត្តាឡីស័ក។ ប្រសិនបើទទួលបានលទ្ធផលតេស្តកូវីដ-១៩ វិជ្ជមាន អ្នកជំងឺអាចដាក់ឱ្យព្យាបាលឬបញ្ជូនទៅកន្លែងព្យាបាលដែលអនុញ្ញាតដោយក្រសួងសុខាភិបាល។ អ្នកដំណើរត្រូវមានឯកសារកក់សណ្ឋាគារសម្រាប់ការធ្វើចត្តាឡីស័ក។ ក្នុងករណីពុំមានការកក់សណ្ឋាគារ ត្រូវត្រៀមសាច់ប្រាក់ចំនួន ២,០០០ ដុល្លារអាមេរិក (សម្រាប់អ្នកដំណើរបរទេស) ដើម្បីតម្កល់នៅច្រកចូលកម្ពុជា សម្រាប់ធានាចំណាយទាំងអស់ពាក់ព័ន្ធនឹងការធ្វើចត្តាឡីស័ក ក្នុងអំឡុងពេលធ្វើចត្តាឡីស័កនៅពេលមកដល់កម្ពុជា។

៣-ក្នុងករណីត្រូវការទិដ្ឋាការដើម្បីធ្វើដំណើរមកកម្ពុជា អ្នកដំណើរត្រូវស្នើសុំទិដ្ឋាការដែលមានសុពលភាពស្របតាមនីតិវិធីនៃច្បាប់ស្តីពីអន្តោប្រវេសន៍ ពីសំណាក់ស្ថានទូតកម្ពុជា ឬពីស្ថានកុងស៊ុលកម្ពុជា។ ការស្នើសុំទិដ្ឋាការត្រូវធ្វើឡើងមុនចេញដំណើរមកកម្ពុជា ដោយរាជរដ្ឋាភិបាលកម្ពុជា មិនទាន់អនុញ្ញាតឱ្យមានទិដ្ឋាការនៅពេលមកដល់ (Visa on Arrival) នៅឡើយ។ អ្នកដំណើរដែលកាន់លិខិតឆ្លងដែននៃប្រទេសដែលមិនតម្រូវឱ្យស្នើសុំទិដ្ឋាការ អាចធ្វើដំណើរមកកម្ពុជា ដោយមិនចាំបាច់ស្នើសុំទិដ្ឋាការទេ។

៤-ការទទួលខុសត្រូវក្នុងការព្យាបាលជំងឺកូវីដ-១៩ សម្រាប់អ្នកដំណើរជាជនបរទេស÷

៤.១.- សម្រាប់អ្នកដំណើរជាជនបរទេស (លើកលែងមន្ត្រីការទូត និងមន្ត្រីអនុវត្តគម្រោងសហប្រតិបត្តិការផ្លូវការ ដែលកាន់ទិដ្ឋាការការទូត (Visa A) និងទិដ្ឋាការផ្លូវការ (Visa B) និងក្រុមគ្រួសារ) ត្រូវទទួលខុសត្រូវខ្លួនឯងក្នុងការព្យាបាល ក្នុងករណីឆ្លងជំងឺកូវីដ-១៩ ឬមានជំងឺផ្សេងទៀត។

៤.២.- អ្នកដំណើរជាជនបរទេស ត្រូវបានលើកទឹកចិត្តឱ្យទិញបណ្ណសន្យារ៉ាប់រងសុខភាពសម្រាប់ព្យាបាលជំងឺកូវីដ-១៩ (COVID-19 Health Insurance Policy) ដែលនៅកម្ពុជាអាចទិញពីការធានារ៉ាប់រងរួមគ្នា (Insurance consortium) តំណាងដោយក្រុមហ៊ុនធានារ៉ាប់រងហ្វតេ តាមរយៈគេហទំព័រ https://www.forteinsurance.com/covid-19-insurance/។

៥-អ្នកដំណើរដែលបានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសមូលដ្ឋានបានពេញលេញ ហើយកំពុងធ្វើចត្តាឡីស័កនៅតាមមណ្ឌលចត្តាឡីស័ក សណ្ឋាគារ ឬគេហដ្ឋាននៅទូទាំងប្រទេស ត្រូវអនុញ្ញាតឱ្យបញ្ចប់ការធ្វើចត្តាឡីស័ក ប្រសិនបើទទួលបានលទ្ធផលតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ (Rapid Test) អវិជ្ជមាន។

**ប្រការ២ .-**

សេចក្តីសម្រេចលេខ៤៥៦ សខល ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១ ស្តីពីនីតិវិធីប្រតិបត្តិស្តង់ដាស្តីពីការធ្វើចត្តាឡីស័ករបស់អ្នកដំណើរមកពីបរទេសដែលបានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសមូលដ្ឋានបានពេញលេញ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣ .-**

ខុទ្ទកាល័យក្រសួងសុខាភិបាល អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល អគ្គាធិការដ្ឋានក្រសួងសុខាភិបាល គណៈប្រតិបត្តិនៃគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ អនុគណៈកម្មការនានាចំណុះឱ្យគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ លេខាធិការដ្ឋានរបស់គណៈប្រតិបត្តិនៃគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ គណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ រាជធានី-ខេត្ត និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសុខាភិបាល ត្រូវអនុវត្តតាមសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១២កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២១

ម៉ម ប៊ុនហេង

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គណៈប្រចាំការនៃ គ.ប.ក.
- ដូចប្រការ៣
- ឯកសារ-កាលប្បវត្តិ

Updated 17-Oct-2021

## AGREEMENT ON VISA EXEMPTION BETWEEM THE KINGDOM OF CAMBODIA AND OTHER COUNTRIES

| No. | Countries | Passport Categories | | | | VISA Exemption Application Date |
|---|---|---|---|---|---|---|
| | | Diplomatic | Service | Special | Normal | |
| **ASEAN Countries** | | | | | | |
| 1 | Brunei Darussalam | 14 days | 14 days | | 14 days | 26-11-2011 |
| 2 | Indonesia | 14 days | 14 days | | 30 days | 22-09-2011 |
| 3 | Lao PDR. | 90 days | 90 days | | 30 days | 01-07-2004 |
| 4 | Malaysia | 30 days | 30 days | | 30 days | 26-05-1997 |
| 5 | Myanmar | 30 days | 30 days | | 14 days | 12-01-2014 |
| 6 | Philippines | 30 days | 30 days | | 30 days | 31-05-2019 |
| 7 | Singapore | 30 days | 30 days | | 30 days | 01-01-2006 |
| 8 | Thailand | 30 days | 30 days | | 14 days | 06-12-2010 |
| 9 | Vietnam | 30 days | 30 days | | 30 days | 05-12-2008 |
| **Other Countries** | | | | | | |
| 10 | Bangladesh | 30 days | 30 days | | Not yet | 21-04-2014 |
| 11 | Belarus | 30 days | 30 days | | Not yet | 07-02-2015 |
| 12 | Brazil | 30 days | 30 days | | Not yet | 24-06-2011 |
| 13 | Chile | 30 days | 30 days | | Not yet | Not yet entry into force |
| 14 | China | 30 days | 30 days | | Not yet | 14-09-2006 |
| 15 | Colombia | 30 days | 30 days | | Not yet | 21-10-2017 |
| 16 | Cuba | In whole mission period | | | Not yet | 24-08-1980 |
| 17 | Ecuador | 30 days | 30 days | | Not yet | 01-07-2013 |
| 18 | Hong Kong (SAR) | 14 days | 14 days | | Not yet | N/V |
| 19 | Hungary | 90 days | 90 days | | Not yet | N/V |
| 20 | India | 60 days | 60 days | | Not yet | 09-05-2002 |
| 21 | Iran | 30 days | 30 days | | Not yet | 10-09-2010 |
| 22 | Japan | In whole mission period or 90 days | | | Not yet | 11-12-2013 |
| 23 | Korea (South) | 60 days | 60 days | | Not yet | 21-12-2006 |
| 24 | Kuwait | 30 days | 30 days | 30 days | Not yet | 11-07-2016 |
| 25 | Mongolia | 30 days | 30 days | | Not yet | 27-09-2012 |
| 26 | Morocco | 30 days | 30 days | | Not yet | 24-04-2019 |
| 27 | Nepal | 30 days | 30 days | | Not yet | 09-06-2019 |
| 28 | Peru | 30 days | 30 days | | Not yet | 10-03-2010 |
| 29 | Romania | 30 days | 30 days | | Not yet | Not yet entry into force |
| 30 | Russia | In whole mission period | | | Not yet | 26-09-1983 |
| 31 | Serbia | 30 days | 30 days | | Not yet | Not yet entry into force |
| 32 | Seychelles | 15 days | 15 days | | 15 days | 08-10-2012 |
| 33 | Timor-Leste | 30 days | 30 days | | Not yet | Not yet entry into force |
| 34 | Turkey | 30 days | 30 days | 30 days | Not yet | 23-08-2015 |
| 35 | Uruguay | 30 days | 30 days | | Not yet | 25-05-2014 |

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល
លេខ...១៧៩...សខក

ថ្ងៃសុក្រ ១០រោច ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២០

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល
គោរពជូន
## ឯកឧត្តមរដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

**កម្មវត្ថុ៖** តម្រូវឱ្យអ្នកបើកបរយន្តហោះ និងបាហុនិកាទាំងអស់ ត្រូវឆ្លងកាត់វិធានសុខាភិបាល។
**យោង ៖** កិច្ចប្រជុំអន្តរក្រសួង របស់គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ នៅទីស្តីការក្រសួងសុខាភិបាល។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបថា ដោយបច្ចុប្បន្ន សភាពការណ៍នៃការរាតត្បាតនៃជំងឺកូវីដ-១៩ នៅមានសន្ទុះកើនឡើងនៅលើសកលលោក និងនៅក្នុងតំបន់។ ជាមួយគ្នាដែរ ដើម្បីទប់ស្កាត់ការនាំចូលនៃវីរុសកូវីដ-១៩ គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ សូមស្នើដល់គ្រប់ក្រុមហ៊ុនអាកាសចរណ៍ទាំងអស់ ដែលហោះហើរចូលមកប្រទេសកម្ពុជា តម្រូវឱ្យអ្នកបើកបរ និងក្រុមបាហុនិកាទាំងអស់ អនុវត្តតាមវិធានសុខាភិបាលរបស់ប្រទេសកម្ពុជា ដែលមានជាធរមាន។

អាស្រ័យហេតុនេះ សូម **ឯកឧត្តមរដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល** ចាត់ចែងអនុវត្ត ដើម្បីរួមគ្នាទប់ស្កាត់ការចម្លងនៃវីរុសកូវីដ-១៩ ចូលក្នុងសហគមន៍។

សូម **ឯកឧត្តមរដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល** ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ។

ជ.រដ្ឋមន្ត្រី
**រដ្ឋលេខាធិការ**

**វេជ្ជ.យក់_សម្បត្តិ**

ទីស្តីការក្រសួងសុខាភិបាល និវេសនដ្ឋានលេខ ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩